

# បាត់ ហើយរកឃើញ

Let's Read

The Asia Foundation



ទីនេះក៏មិនឃើញ ទីនោះក៏មិនឃើញ! តើវាបាត់ទៅណា?



លើសាឡុងក៏មិនឃើញ។ ក្រោមគ្រែក៏មិនឃើញ។



នៅក្នុងប្រអប់ក៏មិនឃើញ។ នៅក្រោមអាវប្អូនស្រីខ្ញុំក៏មិនឃើញ។



មិននៅក្រោមខ្នើយ មិននៅក្នុងកាតាបខ្ញុំ◌ុ។ ហ៊ី ហ៊ី! តើវា
បាត់ទៅណាហើយ?



ខ្ញុំរកនៅគ្រប់បន្ទប់ទាំងអស់ ហើយក្រោមសៀវភៅក៏មើលអស់ហើយដែរ។



ខ្ញុំបានរកនៅក្រោមកៅអី នៅក្រោមជើងម៉ារួចហើយ។ តើវាបាត់ទៅណាហើយ?



ភ្លាមនោះ លោកយាយបានដើរមកដល់ គាត់និយាយថា «មើលនែ យាយរកឃើញរបស់មួយក្នុងសួន។»



លោកយាយបាននិយាយទាំងសើច ហ៊ិសៗ ហ៊ុះៗ «វាអាច យោលចុះឡើង វាអាចលោត។ វាអាចបង្វិលបាន វាអាចសំយុង ចុះឡើង។»



អ៊ូ អរគុណណាស់លោកយាយ! លោកយាយបានរកឃើញយ៉ូយ៉ូសំណព្វចិត្តរបស់ខ្ញុំហើយ!



«យ៉ូយ៉ូ? ឈ្មោះអីកំប្លែងម្ល៉េះ! របស់លេងអីគួរឱ្យចង់សើចណាស់! យាយចង់លេងវា។ វាពិតជាសប្បាយលេងមែន!»



សើច សើច សើចនោះសើច! លោកយាយលេងយ៉ូយ៉ូរបស់ខ្ញុំ។ ពេញមួយថ្ងៃតែម្ដង!

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Lost and Found*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Solyda Say and Sodany Ouch